ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.................................................

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី កិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និង ធនាគាររដ្ឋវៀតណាម និងការចុះអនុស្សរណៈយោគយល់ថ្មី

នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និង ធនាគាររដ្ឋវៀតណាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងឯកឧត្តម Le Minh Hung ទេសាភិបាលធនាគាររដ្ឋវៀតណាម ។

កិច្ចប្រជុំបានប្រារព្ធឡើងក្នុងគោលបំណងពង្រឹងចំណងសាមគ្គីភាព ភាតរភាព មេត្រីភាព និងកិច្ចសហប្រតិបត្តិការល្អជាប្រពៃណីដែលស្ថាប័ន ក៏ដូចជាប្រទេសទាំងពីរមានតាំងពីយូរលង់ណាស់មកហើយ។ លើសពីនេះ គណៈប្រតិភូទាំងពីរបានផ្លាស់ប្តូរព័ត៌មានស្តីពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងការរីកចម្រើន វិស័យធនាគារព្រមទាំងពិនិត្យមើលពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការនាពេលកន្លងមក និងជាពិសេសកំណត់ទិសដៅអាទិភាពចម្បងៗ សំដៅពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ជាប្រពៃណីឱ្យកាន់តែរឹងមាំប្រកបដោយចីរភាព សម្រាប់ជាគុណប្រយោជន៍ដល់ស្ថាប័ននិងប្រទេសទាំងពីរ។

ឆ្លៀតឱកាសកិច្ចប្រជុំទ្វេភាគីលើកនេះ ធនាគារកណ្តាលទាំងពីរបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ថ្មី ដែលបានធ្វើបច្ចុប្បន្នកម្មលើអនុស្សរណៈយោគយល់ចាស់តាំងពីឆ្នាំ២០០៧មក ស្របតាមការរីកចម្រើននៃកិច្ចសហប្រតិបត្តិការរបស់ធនាគារកណ្តាលទាំងពីរ និងការរីកចម្រើននៃទំនាក់ទំនងលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងហិរញ្ញវត្ថុនៃប្រទេសទាំងពីរ។ អនុស្សរណៈយោគយល់ថ្មីនេះ នឹងបើកលទ្ធភាពឱ្យមន្ត្រីនៃធនាគារកណ្តាលទាំងពីរបង្កើនកិច្ចសហប្រតិបត្តិការកាន់តែទូលំទូលាយ និងស៊ីជម្រៅទៅលើការងារចម្បងៗនៃមុខងារ-ភារកិច្ចរបស់ធនាគារកណ្តាល។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh